**លក្ខខណ្ឌ:**

**កម្មវិធីប្រម៉ូសិន សេវាបើកប្រាក់បៀវត្សរបស់ធនាគារ អ អេច ប៊ី(ខេមបូឌា)**

១. កម្មវិធីប្រម៉ូសិនចាប់ផ្តើមពីថ្ងៃទី ០២ ខែមករា ២០២៥ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥ (សុពលភាពប្រម៉ូសិន)។
២. កម្មវិធីប្រម៉ូសិននេះអនុញ្ញាតទាំងអតិថិជនចាស់ និងអតិថិជនថ្មី។
៣. ដើម្បីចូលរួមកម្មវិធីប្រម៉ូសិនបាន អតិថិជន ត្រូវតែបំពេញលក្ខខណ្ឌដូចខាងក្រោម (អតិថិជនគ្រប់លក្ខខណ្ឌ) ៖

- អតិថិជនថ្មី គឺជាអតិថិជនដែលមិនធ្លាប់បានប្រើប្រាស់សេវាបើកប្រាក់បៀវត្សជាមួយធនាគារ អ អេច ប៊ី (ទូទាត់/ទទួល)
- អតិថិជនចាស់ គឺជាអតិថិជនដែលបានកំពុងប្រើប្រាស់សេវាបើកប្រាក់បៀវត្សជាមួយធនាគារ អ អេច ប៊ី (ទូទាត់/ទទួល)

  **សម្រាប់និយោជក៖** ជារូបវន្តបុគ្គល ឬនីតិបុគ្គល (សហគ្រាសខ្នាតតូចនិងមធ្យម, ពាណិជ្ជកម្ម, សាជីវកម្ម)

  **សម្រាប់និយោជិត៖** ជារូបវន្តបុគ្គល

៤. លក្ខខ្ឌិកៈនៃកម្មវិធីប្រម៉ូសិនមានដូចចែងខាងក្រោម៖
ដើម្បីទទួលបានសិទ្ធិចូលរួមកម្មវិធីប្រម៉ូសិន៖

- ក្រុមហ៊ុន/និយោជក ត្រូវមានគណនីសន្សំផ្ទាល់ខ្លួន(គណនីមេសម្រាប់ធ្វើប្រតិបត្តិការទូទាត់ប្រាក់បៀវត្សទៅនិយោជិត) ជាមួយធនាគារ អ អេច ប៊ី ដោយរាប់បញ្ចូលប្រភេទគណនីដូចជា គណនីចរន្ត គណនីចរន្តAdvantage គណនីចរន្តPremier គណនីសន្សំឆ្លាតវៃ គណនីសន្សំ។
- ចុះឈ្មោះប្រើប្រាស់សេវាបើកប្រាក់បៀវត្សរបស់ធនាគារ អ អេច ប៊ី ដោយធ្វើប្រតិបត្តិការតាមមធ្យោបាយណាមួយ រួមមានតាមរយៈបញ្ជរ បេឡា នៅតាមសាខាណាមួយ របស់ធនាគារ អ អេច ប៊ី ឬតាមកម្មវិធីគ្រប់គ្រងសាច់ប្រាក់ Reflex។
- និយោកជកត្រូវតែធ្វើប្រតិបត្តិការបើកប្រាក់បៀវត្សជាមួយ ធនាគារ អ អេច ប៊ី ទៅកាន់និយោជិតរបស់ខ្លួន តាមរយៈបញ្ជរបេឡា នៅតាមសាខាណាមួយ របស់ធនាគារ អ អេច ប៊ី ឬតាម កម្មវិធីគ្រប់គ្រងសាច់ប្រាក់ Reflex ឬ កម្មវិធីទូរសព្ទ GoWave by RHB អំឡុងពេលសុពលភាពប្រូម៉ូសិន។

៥. អតិថិជនគ្រប់លក្ខខណ្ឌ នឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីកម្មវិធីប្រូម៉ូសិន បន្ទាប់ពីគោរពតាមលក្ខខណ្ឌត្រឹមត្រូវដូចបានចែងខាងលើក្នុងចំនុចទី ៣ និង ៤។ អតិថិជនចាស់ ដែលជានិយោជិត អាចទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីកម្មវិធីប្រូម៉ូសិន ដែលស្ថិតនៅក្រោមកញ្ចប់អត្ថប្រយោជន៍របស់និយោជិត និងអតិថិជនចាស់ ដែលជានិយោជក ក៏អាចចូលរួមរីករាយទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីកម្មវិធីប្រូម៉ូសិន ដែលស្ថិតនៅក្រោមកញ្ចប់អត្ថប្រយោជន៍របស់និយោជក។
៦. សម្រាប់ក្រុមហ៊ុន/និយោជក ដែលជាអតិថិជនថ្មី នឹងទទួលបានទឹកប្រាក់ត្រឡប់មកវិញ ដូចមានចែងខាងក្រោម៖

| ចំនួនទឹកប្រាក់បើកបៀវត្ស (ដុល្លារអាមេរិក ឬសមមូលដុល្លារអាមេរិក) | អត្រានៃ ចំនួនទឹកប្រាក់ត្រឡប់ * | ចំនួនទឹកប្រាក់ត្រឡប់ អតិបរមាផ្តល់ជូន ក្នុងមួយគណនី ក្នុងមួយខែ | រយៈពេលផ្តល់ជូន ទឹកប្រាក់ត្រឡប់ |
|---|---|---|---|
| គ្រប់ចំនួនទឹកប្រាក់ | ០,៥០% | ៤០០ ដុល្លារអាមេរិក | ៦ខែ ឬដង |

**ចំនួនទឹកប្រាក់ត្រឡប់ គឺអាស្រ័យលើចំនួនទឹកប្រាក់បើកបៀវត្សសរុបប្រចាំខែ*

៦.១ ចំនួនទឹកប្រាក់បើកបៀវត្សប្រចាំខែ ត្រូវបានកំណត់ជាគោលក្នុងការគណនារកចំនួនទឹកប្រាក់ត្រឡប់ ដើម្បីផ្តល់ជូនក្រុមហ៊ុន/និយោជកក្នុងអំឡុងពេលសុពលភាពនៃកម្មវិធីប្រូម៉ូសិន។

៦.២ ដើម្បីទទួលបានទឹកប្រាក់ត្រឡប់ និយោជក ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវតែជាអតិថិជនថ្មី
- ធ្វើប្រតិបត្តិការសេវាបើកប្រាក់បៀវត្សតាមរយៈមធ្យោបាយណាមួយ រួមមាន តាមរយៈបញ្ជរបេឡា នៅតាមសាខាណាមួយរបស់ធនាគារ អ អេច ប៊ី ឬ តាម កម្មវិធីគ្រប់គ្រងសាច់ប្រាក់ Reflex ឬ កម្មវិធីទូរសព្ទ GoWave by RHB
- ត្រូវមាននិយោជិតយ៉ាងតិច ៥នាក់ឡើងទៅ

៦.៣ និយោជក ត្រូវតែធ្វើប្រតិបត្តិការបើកប្រាក់បៀវត្សប្រចាំខែជាមួយ ធនាគារ អ អេច ប៊ី ក្នុងអំឡុងពេលសុពលភាពនៃកម្មវិធីប្រូម៉ូសិន ។ ទឹកប្រាក់ត្រឡប់នឹងផ្តល់ជូន ៦ខែ ឬដង រាប់ចាប់ពីការធ្វើប្រតិបត្តិការបើកប្រាក់បៀវត្សលើកទីមួយ។ បញ្ជាក់ ទឹកប្រាក់ត្រឡប់នឹងមិនត្រូវបានផ្តល់ជូន ប្រសិនបើមិនបានធ្វើប្រតិបត្តិការក្នុងខែនោះ។

៦.៤ ការផ្តល់ជូនទឹកប្រាក់ត្រឡប់ នឹងផ្ទេរចូលក្នុងគណនីអតិថិជនគ្រប់លក្ខខណ្ឌ នៅក្នុងខែបន្ទាប់។

៦.៥ ការផ្តល់ជូនទឹកប្រាក់ត្រឡប់ អនុញ្ញាតតែនិយោជកថ្មីតែប៉ុណ្ណោះ។

៦.៦ ការផ្តល់ជូននេះ ធ្វើឡើងតាមលក្ខខណ្ឌ អ្នកមកមុននឹងទទួលបានមុន រហូតដល់អស់ពីការកំណត់។

៦.៧ ការផ្តល់ជូនទឹកប្រាក់ត្រឡប់ នឹងផ្តល់ជារូបិយប័ណ្ណខ្មែររៀល ឬដុល្លារអាមេរិក។

៦.៨ ទឹកប្រាក់ត្រឡប់ នឹងត្រូវផ្ទេរចូលទៅក្នុងគណនីរបស់និយោជក ដោយផ្អែកលើរូបិយប័ណ្ណរបស់គណនី។ ប្រសិនបើមានការស្នើសុំផ្ទេរទឹកប្រាក់ត្រឡប់នោះទៅគណនីផ្សេងទៀតគឺមិនត្រូវបានអនុញ្ញាតឡើយ។

៦.៩ ធនាគារ អ អេច ប៊ី សូមរក្សាសិទ្ធិក្នុងការមិនផ្តល់ជូនទឹកប្រាក់ត្រឡប់ដល់អតិថិជន ប្រសិនបើយើងរកឃើញថាមានការបំពានលើលក្ខន្តិកៈនៃកម្មវិធីប្រម៉ូសិននេះ ឬក្នុងករណីដែលកញ្ចប់ថវិកាត្រូវបានអស់។

៧. ក្រុមហ៊ុន/និយោជក ត្រូវជូនដំណឹងមកកាន់ ធនាគារ អ អេច ប៊ី រាល់មានការផ្លាស់ប្តូរគណនីនិយោជិតរបស់ខ្លួន សម្រាប់សេវាកម្មបើកប្រាក់បៀវត្ស (និយោជិតថ្មី និងនិយោជិតលាឈប់ពីការងារ)។

៨. កម្មវិធីប្រូម៉ូសិននេះមិនមានសុពលភាពក្នុងការភ្ជាប់ជាមួយប្រូម៉ូសិន ឬកម្មវិធីផ្សេងទៀត ដែលធ្វើឡើងដោយ ធនាគារ អ អេច ប៊ី លុះត្រាតែមានការបញ្ជាក់ផ្សេងទៀត។

៩. តាមរយៈការចូលរួមក្នុងកម្មវិធីប្រូម៉ូសិននេះ ម្ចាស់គណនីទាំងអស់ (និយោជក និងនិយោជិត) ត្រូវបានចាត់ទុកថាបានទទួលយក និងយល់ព្រមតាមលក្ខខណ្ឌដែលមានចែងទាំងអស់នេះ។

១០. ធនាគារ អ អេច ប៊ី សូមរក្សាសិទ្ធិក្នុងការបន្ថែម កែប្រែ ឬ កែសម្រួលលក្ខន្តិៈផ្សេងៗ និង/ឬ លុបចោលប្រម៉ូសិននេះគ្រប់ពេលវេលា ហើយនិងធ្វើការជូនដំណឹងដំណាលគ្នា ដល់អតិថិជនតាមរយៈបណ្តាញមធ្យោបាយណាមួយដែលសមស្របរបស់ធនាគារ។

-ចប់-